**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញលិខិតស្នើសុំ របស់លោក ជា ចំរើន ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

### សំរេច

**មាត្រា ១ :** អនុញ្ញាតអោយបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា " សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា " (**CHAMROEUN UNIVERSITY OF POLY-TECHNOLOGY**) ហៅកាត់ជាភាសាខ្មែរ " ស.ច.ព " និងហៅកាត់ជាភាសាអង់គ្លេស " CUP " ។ សាកលវិទ្យាល័យនេះស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា និងមានទីតាំងគោលស្ថិតនៅអាគារលេខ ៨៨ ផ្លូវលេខ ៣៥០

សង្កាត់ទួលស្វាយព្រៃទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បណ្តុះបណ្តាលរយៈពេលខ្លី ក្រោម ២ឆ្នាំទៅតាមជំនាញវិជ្ជាជីវៈ ។
- ថ្នាក់បរិញ្ញាប័ត្ររងសិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៧០ក្រេឌីត ។
- ថ្នាក់បរិញ្ញាប័ត្រសិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ ក្រេឌីត ។
- ថ្នាក់អនុបណ្ឌិតសិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៦០ ក្រេឌីត ។
- ថ្នាក់បណ្ឌិតសិក្សារយៈពេលយ៉ាងតិច ៣ឆ្នាំ ត្រូវនឹង ៥៤ ក្រេឌីត ។

**មាត្រា ៣ :** សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាមាន :

១. មហាវិទ្យាល័យ វិទ្យាសាស្ត្រអប់រំ
២. មហាវិទ្យាល័យ វិទ្យាសាស្ត្របច្ចេកវិទ្យា និង គណិតវិទ្យាអនុវត្ត
៣. មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
៤. មហាវិទ្យាល័យ សណ្ឋាគារ និង ទេសចរណ៍
៥. មហាវិទ្យាល័យ មនុស្សសាស្ត្រ និង វិទ្យាសាស្ត្រនយោបាយ
៦. មហាវិទ្យាល័យ នីតិសាស្ត្រ
៧. មហាវិទ្យាល័យ កសិកម្ម និង អភិវឌ្ឍន៍ជនបទ
៨. មហាវិទ្យាល័យ ភាសាបរទេស
៩. មជ្ឈមណ្ឌលបណ្តុះបណ្តាលលេខាធិការ និង រដ្ឋបាល ។

ទៅថ្ងៃអនាគត សាកលវិទ្យាល័យនេះអាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេស ដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤** សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាមានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យនិងសំរេចលើគោលនយោបាយ និង ផែនការអភិវឌ្ឍ របស់សាកលវិទ្យាល័យ និង មានក្រុមប្រឹក្សាបណ្ឌិតវិទ្យាសាស្ត្រមួយដែលសមាជិកក្រុមប្រឹក្សានេះមានសញ្ញាប័ត្រកំរិតបណ្ឌិត សំរាប់ ពិនិត្យ និង ផ្តល់យោបល់លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

-ថ្នាក់បរិញ្ញាប័ត្ររងៈបេក្ខជនទាំងពីរភេទបានបញ្ចប់ថ្នាក់ទី១២នៃមធ្យមសិក្សាចំណេះទូទៅយ៉ាងទាប ។

- ថ្នាក់បរិញ្ញាប័ត្រៈ បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់អនុបណ្ឌិត : បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្របរិញ្ញាប័ត្រ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់បណ្ឌិត : បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្រអនុបណ្ឌិត រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

- សាកលវិទ្យាល័យត្រូវគោរពតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំនត់អំពីការជ្រើសរើសអោយចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**មាត្រា ៦ :** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាមានភារកិច្ច :

- ជ្រើសរើស សិស្ស-និស្សិត អោយចូលរៀន និង ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និងការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៧ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យនេះ និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវបានទទួលសញ្ញាប័ត្រតាមកំរិត និង តាមឯកទេសដែលបានសិក្សា។ សញ្ញាប័ត្រនេះត្រូវបានផ្តល់អោយ ដោយសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះបានបំពេញនិងអនុវត្ត តាមគោលការណ៍របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា មានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្ត និងប្រតិបត្តិ តាមអនុក្រឹត្យនេះ ។

**មាត្រា ៩ .** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញៈ ថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

"ដើម្បីជូនជ្រាប"

- ដូចមាត្រា ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ